ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

# សេចក្តីជូនដំណឹង
## ស្តីពីប្រព័ន្ធទូរស័ព្ទបម្រើសេវាអតិថិជននៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម សូមជម្រាបជូន លោក-លោកស្រី ម្ចាស់សហគ្រាស និងអភិបាលក្រុមហ៊ុន មេត្តាជ្រាបជាព័ត៌មានថា បច្ចុប្បន្ន នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មកំពុងរៀបចំតម្លើងប្រព័ន្ធបម្រើសេវាទូរស័ព្ទថ្មីប្រភេទអេឡិចត្រូនិក ជំនួសប្រព័ន្ធទូរស័ព្ទចាស់ដែលមានស្រាប់ ដើម្បីបង្កើនលទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការផ្តល់សេវាចុះបញ្ជីពាណិជ្ជកម្មឲ្យកាន់តែទូលំទូលាយជាងមុន ជៀសវាងការកកស្ទះនៃការហៅចូល និងឆ្លើយតបទៅនឹងតម្រូវការនៃការស្នើសុំសេវា។

អាស្រ័យហេតុនេះ សូម លោក-លោកស្រី ម្ចាស់សហគ្រាស និងអភិបាលក្រុមហ៊ុន មេត្តាយោគយល់ និងអធ្យាស្រ័យនូវរាល់ភាពអាក់អួលទាំងឡាយណា ដែលអាចកើតមានក្នុងការហៅចូលមកកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម រហូតដល់ប្រព័ន្ធទូរស័ព្ទថ្មីប្រភេទអេឡិចត្រូនិកត្រូវបានតម្លើងរួចរាល់ជាស្ថាពរ។

ដោយឡែក នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៅតែព្យាយាមទទួលការហៅចូល ពាក់ព័ន្ធនឹងសេវាព័ត៌មានចុះបញ្ជីពាណិជ្ជកម្ម តាមរយៈទូរស័ព្ទដូចខាងក្រោម៖

-023 866 459 ក្នុងករណីការតម្កល់ឯកសារច្បាប់ដើម និងរាល់បញ្ហាប្រតិវេទន៍

-023 866 050 ក្នុងករណីការឃើតយ៉ាវផ្សេងៗ។

ចំពោះរាល់ព័ត៌មានលម្អិតផ្សេងៗ លោក-លោកស្រី អាចស្វែងរកបាននៅគេហទំព័រដើមចុះបញ្ជីពាណិជ្ជកម្ម www.businessregistration.moc.gov.kh ឬអញ្ជើញទំនាក់ទំនងមកបញ្ជរផ្តល់សេវាចុះបញ្ជីពាណិជ្ជកម្ម ដែលមានទីតាំងនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគារទី៣ ជាន់ទី៣នាទីស្តីការក្រសួងពាណិជ្ជកម្ម។

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម សង្ឃឹម និងជឿជាក់ថា លោក-លោកស្រី ម្ចាស់សហគ្រាស និងអភិបាលក្រុមហ៊ុន មេត្តាយោគយល់ និងផ្តល់ការអធ្យាស្រ័យពាក់ព័ន្ធនឹងប្រព័ន្ធទូរស័ព្ទដែលមានស្រាប់។